ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឆ្នាំទី២១ លេខ៧៤ ត្រីមាសទី០៤ ឆ្នាំ២០២១

# រាជកិច្ច

ផ្សាយចេញពី

ទីស្តីការគណៈរដ្ឋមន្ត្រី

សារបាន

ព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច បទបញ្ជា សារាចរ ប្រកាស

# ក

# មាតិកា

## I~ព្រះរាជខុទ្ទកាល័យព្រះមហាក្សត្រ

### ព្រះរាជក្រឹត្យ


១៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥៣ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ប៊ួយ ឌឹកធៀន** **(BUI DUC TUYEN)** ជនជាតិវៀតណាម សញ្ជាតិវៀតណាម ដោយប្ដូរឈ្មោះជា **បូ សុផាត** (**BO SOPHAT**) ៩១២៥

១៨-១២-២០២១ -ព្រះរាជក្រឹត្យ នស/រកត/១២២១/៨៥៤ ស្ដីពី ការផ្ដល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **វ៉ាង ជីងយៀន** **(WANG CHING-YEN)** ជនជាតិចិន សញ្ជាតិចិន (តៃវ៉ាន់) ៩១២៦


## II~រាជរដ្ឋាភិបាល

### ១~អនុក្រឹត្យ


២៤-៨-២០២១ -អនុក្រឹត្យលេខ ១៦៤ អនក្រ.បក ស្ដីពី ការផ្លាស់ប្ដូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា ៩១២៧

២២-១២-២០២១ -អនុក្រឹត្យលេខ ៥៨៣ អនក្រ.តត ស្ដីពី ការតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនភ្លើនត្រេជ អាណត្តិទី៨ ៩១៣៨

២៣-១២-២០២១ -អនុក្រឹត្យលេខ ៥៨៤ អនក្រ.តត ស្ដីពី ការបញ្ចប់មុខតំណែងមន្ត្រីរាជការ ៩១៤០

២៣-១២-២០២១ -អនុក្រឹត្យលេខ ៥៨៥ អនក្រ.តត ស្ដីពី ការតែងតាំងមន្ត្រីរាជការ ៩១៤១


### ២~សេចក្ដីសម្រេច


២-១២-២០២១ -សេចក្ដីសម្រេចលេខ ១១៨ សសរ ស្ដីពី ការផ្លាស់ប្ដូរសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ និងខេត្តកំពត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា ៩១៤២


### ៣~សារាចរណែនាំ


៣១-១២-២០២១ -សារាចរណែនាំលេខ ០៧ សរណន ស្ដីពី ការអនុវត្តការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទសម្រាប់ឆ្នាំ២០២១ និង២០២២ ៩១៤៤


## III~ការងារបណ្ដាក្រសួង

### ១~ទីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ


២៥-១១-២០២១ -ប្រកាសរួមលេខ ៧៩៦ សហវ.ប្រក ស្ដីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ៩១៤៥

## ២~ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍


| | | |
|---|---|---|
| ១១-២-២០២១ | -ប្រកាសលេខ ០៥៥ ឧវបន.កឧ.ប្រក ០២ ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ព្រីនអិកស៍ ជីភី (ខេមបូឌា) ហ្វេកធើរី ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ និងគ្រឿងបន្សំកាបូប | ៩១៥៩ |
| ៦-៤-២០២១ | -ប្រកាសលេខ ១៤៤ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ផលិតម្សៅជំឡូងមី ចំកាត់ បង្កើតរោងចក្រកែច្នៃផ្លែឈើ | ៩១៦២ |
| ៦-៤-២០២១ | -ប្រកាសលេខ ១៤៦ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យ៉កម៉ាស (ខេមបូឌា) ហ្គាមេន អិមអេហ្វជី បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ សម្លៀកបំពាក់ពេទ្យ មួក ស្រោមដៃ បូ ចាក់ ស្រោមជើង ប៉ាក់ ម៉ាស់ បោះពុម្ព និងបោកគក់ | ៩១៦៥ |
| ៦-៤-២០២១ | -ប្រកាសលេខ ១៤៧ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ភ្នំពេញ ស៊ូហ្គើរ បង្កើតរោងចក្រ ផលិតស្ករស | ៩១៦៨ |
| ៨-៤-២០២១ | -ប្រកាសលេខ ១៤៨ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អិល អេស ខនស្រ្តាក់សិន (លី ស៊ើរីស-ខេមបូឌា) ភីធីអ៊ី អិលធីឌី បង្កើតរោងចក្រ លាយកៅស៊ូបេទីមីណឺ | ៩១៧១ |
| ៨-៤-២០២១ | -ប្រកាសលេខ ១៤៩ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន យូធីឡៃថ៍ អេឡិកទ្រីក ឯ.ក បង្កើតរោងចក្រ ផលិតអំពូលភ្លើងលំអ | ៩១៧៤ |
| ៨-៤-២០២១ | -ប្រកាសលេខ ១៥០ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្កាយវើត ហ្វេសិន (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩១៧៧ |
| ៨-៤-២០២១ | -ប្រកាសលេខ ១៥១ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ញូ ហ្វូម៉ា ខសធ្យូម (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ កាត់ដេរសម្លៀកបំពាក់ | ៩១៨០ |
| ២៣-៩-២០២១ | -ប្រកាសលេខ ៣៤៥ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន ស្តាវីត (ខេមបូឌា) ឯ.ក បង្កើតរោងចក្រ ផលិតកាបូបគ្រប់ប្រភេទ | ៩១៨៣ |
| ២៨-៩-២០២១ | -ប្រកាសលេខ ៣៥២ ឧវបន.កឧ.ប្រក ស្តីពី ការអនុញ្ញាតឱ្យក្រុមហ៊ុន អង្គរ ដេលី ហ្វ៊ូដ បង្កើតរោងចក្រ ផលិតទឹកផ្លែឈើ | ៩១៨៦ |


## ៣~ទីស្តីការរដ្ឋមន្ត្រីក្រសួងរ៉ែ និង ថាមពល


| | | |
|---|---|---|
| ៨-១២-២០២០ | -ប្រកាសលេខ ០៦៤៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៦៤៤ រថ.អប្រក.លអ ចុះថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០២០ | ៩១៨៩ |
| ១០-១២-២០២០ | -ប្រកាសលេខ ០៦៤៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៤៥ រថ.អប្រក.លអ ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ២០២០ | ៩១៩៣ |
| ១១-១២-២០២០ | -ប្រកាសលេខ ០៦៦១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៦១ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ | ៩១៩៧ |

១១-១២-២០២០ -ប្រកាសលេខ ០៦៦៣ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៦៣ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២០១

១១-១២-២០២០ -ប្រកាសលេខ ០៦៦៤ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៦៤ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២០៥

១១-១២-២០២០ -ប្រកាសលេខ ០៦៦៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៦៦ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២០៩

១១-១២-២០២០ -ប្រកាសលេខ ០៦៦៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៦៨ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២១៣

១១-១២-២០២០ -ប្រកាសលេខ ០៦៦៩ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៦៦៩ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២១៧

១១-១២-២០២០ -ប្រកាសលេខ ០៦៧០ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៧០ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២២១

១១-១២-២០២០ -ប្រកាសលេខ ០៦៧១ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៧១ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២២៥

១១-១២-២០២០ -ប្រកាសលេខ ០៦៧២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០៦៧២ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២២៩

១១-១២-២០២០ -ប្រកាសលេខ ០៦៧៥ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៧៥ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២៣៣

១១-១២-២០២០ -ប្រកាសលេខ ០៦៧៦ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៧៦ រថ.អប្រក.លអ ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០២០ ៩២៣៧

១៦-១២-២០២០ -ប្រកាសលេខ ០៦៧៨ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ ប្រេងឥន្ធនៈលេខ ០៦៧៨ រថ.អប្រក.លអ ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០២០ ៩២៤១

១៧-២-២០២១ -ប្រកាសលេខ ០២៣២ រថ.អប្រក.ប្រក ស្តីពី លក្ខខណ្ឌនៃលិខិតអនុញ្ញាតដំណើរការស្ថានីយ រួមប្រេង និងឧស្ម័នឥន្ធនៈលេខ ០២៣២ រថ.អប្រក.លអ ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០២១ ៩២៤៥

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/៤៥៣

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១ :** ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់លោក **ប៊ូយ ឌឹកធ្វៀន** (BUI DUC TUYEN) ជនជាតិ **វៀតណាម** សញ្ជាតិ **វៀតណាម** កើតនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៨៤ នៅខេត្តថាញ់ហ័រ សាធារណរដ្ឋសង្គមនិយមវៀតណាម ដោយប្តូរឈ្មោះជា **បូ សុផាត** ( BO SOPHAT )។

**មាត្រា២ :** សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

នសីហមុនី

**នរោត្តម សីហមុនី**

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២១

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ឧបនាយករដ្ឋមន្ត្រីប្រចាំការ
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន

# ព្រះរាជក្រឹត្យ

នស/រកត/១២២១/ ៤៥៤

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខនស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០០៨ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

**មាត្រា១** : ផ្តល់សញ្ជាតិខ្មែរ ដោយសញ្ជាតូបនីយកម្មដល់អ្នកស្រី **វ៉ាង ជីងយៀន** (WANG CHING-YEN) ជនជាតិ ចិន សញ្ជាតិ ចិន(តៃវ៉ាន់) កើតនៅថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៣ នៅខេត្តតៃវ៉ាន់ សាធារណរដ្ឋចិន។

**មាត្រា២** : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ចារសរ. ២១១២.៤៧៥

ធ្វើនៅព្រះបរមរាជវាំង, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០២១

នរោត្តម សីហមុនី

**នរោត្តម សីហមុនី**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ ៖** ១៦៤ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២០ ស្តីពីការចុះបញ្ជីអាជីវកម្ម តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីការគ្រប់គ្រងការផ្លាស់ប្តូរទិន្នន័យរវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយនិងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជន ក្នុងក្របខណ្ឌអន្តរប្រតិបត្តិការ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា "**ថ.ផ.ឱ.**" (Cambodia Data Exchange "**CamDX**") ប្រកបដោយសុវត្ថិភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះរាល់ប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យតាមរយៈ **ថ.ផ.ឱ.** ក្នុងវិស័យសាធារណៈ ដែលមានជាអាទិ៍ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងវិស័យឯកជនដែលជាសមាជិករបស់ **ថ.ផ.ឱ.**។

ការផ្លាស់ប្តូរទិន្នន័យពាក់ព័ន្ធនឹងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ត្រូវអនុវត្តតាមលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ជាធរមាន។

**មាត្រា៣.-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់និយមន័យ ដូចក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធទី១ នៃអនុក្រឹត្យនេះ។

## ជំពូកទី២

## អំពី ថ.ផ.ឱ.

**មាត្រា៤.-**

**ថ.ផ.ឱ.** ជាថ្នាលបច្ចេកវិទ្យាព័ត៌មានរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលត្រូវបានបង្កើតឡើងសម្រាប់ផ្លាស់ប្តូរទិន្នន័យ ដោយប្រើប្រាស់សន្ទានកម្មនៃកម្មវិធីកុំព្យូទ័ររវាងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌-មានមួយទៀតក្នុងវិស័យសាធារណៈ និងជាមួយវិស័យឯកជនដែលជាសមាជិករបស់ **ថ.ផ.ឱ.** ដោយសុវត្ថិភាព តាមរយៈប្រព័ន្ធអ៊ីនធឺណិត ឬបណ្តាញតភ្ជាប់ឌីជីថលផ្សេងៗ។

គំនូសតាងនៃប្រព័ន្ធអន្តរប្រតិបត្តិការរបស់ **ថ.ផ.ឱ.** ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធទី២ នៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

ទិន្នន័យដែលត្រូវផ្លាស់ប្តូរតាមរយៈ **ថ.ផ.ឆ.** ត្រូវបានធ្វើកូដនីយកម្មនិងចុះហត្ថលេខាឌីជីថល ដើម្បីធានាបាននូវសុវត្ថិភាព សុចរិតភាព និងសុក្រឹតភាពនៃទិន្នន័យ ព្រមទាំងត្រូវបានធ្វើកំណត់ត្រាអេឡិចត្រូនិកពីការផ្លាស់ប្តូរទិន្នន័យ។

**មាត្រា៦.-**

រាល់ការផ្លាស់ប្តូរទិន្នន័យតាមរយៈ **ថ.ផ.ឆ.** ត្រូវបានធានាថាទិន្នន័យមិនត្រូវបានរក្សាទុក នៅក្នុងប្រព័ន្ធបច្ចេក-វិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.** និង/ឬចែកចាយជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យដើមទេ។

## ជំពូកទី៣

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ "**ក.ស.ហ.វ.**" ជាសេនាធិការជូនរាជរដ្ឋាភិបាលកម្ពុជា ក្នុងការដឹកនាំនិងគ្រប់គ្រងលើ **ថ.ផ.ឆ.** សំដៅជំរុញការទទួលយក និងបរិវត្តកម្មឌីជីថលស្របតាមក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថល នៅព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៨.-**

ប្រតិបត្តិការរបស់ **ថ.ផ.ឆ.** ត្រូវគ្រប់គ្រងដោយប្រតិបត្តិករ **ថ.ផ.ឆ.** ដែលមាន **ក.ស.ហ.វ.** ជាអាណាព្យាបាលបច្ចេកទេស និងហិរញ្ញវត្ថុ និងស្ថិតក្រោមការត្រួតពិនិត្យរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដោយអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

ការរៀបចំនិងការប្រព្រឹត្តទៅរបស់ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែកតាមសំណើរបស់រដ្ឋមន្ត្រី **ក.ស.ហ.វ.**។

## ជំពូកទី៤

## សមាជិកភាព និងភារកិច្ចរបស់សមាជិក

### ផ្នែកទី១

### វិធានរួម

**មាត្រា៩.-**

សមាជិក **ថ.ផ.ឆ.** ត្រូវបានចែកចេញជាពីរប្រភេទ រួមមាន៖

- សមាជិកភាពដោយស្វ័យប្រវត្តិ និង
- សមាជិកភាពដោយការស្នើសុំ។

សមាជិកនីមួយៗ អាចជាអ្នកទទួលទិន្នន័យ និង/ឬជាអ្នកផ្តល់ទិន្នន័យ។

**មាត្រា១០.-**

សមាជិកភាពដោយស្វ័យប្រវត្តិ ជាវិស័យសាធារណៈ ដែលមានជាអាទិ៍ ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល គ្រឹះស្ថានសាធារណៈរដ្ឋបាល សហគ្រាសសាធារណៈ អង្គភាពស្វ័យភាពហិរញ្ញវត្ថុដទៃទៀត និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

សមាជិកភាពដោយការស្នើសុំ ជាវិស័យឯកជន ដែលមានជាអាទិ៍ ក្រុមហ៊ុន/សហគ្រាសពាណិជ្ជកម្ម សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា១១.-**

សមាជិក **ថ.ផ.ឆ.** មានភារកិច្ចដូចតទៅ÷

- ផ្លាស់ប្តូរនិងប្រើប្រាស់ទិន្នន័យស្របតាមបែបបទនីតិវិធីដូចមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តជាធរមាន ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយ **គ.ស.ហ.ទ.** ឬជាមួយប្រតិបត្តិករ **ថ.ផ.ឆ.**
- រៀបចំធ្វើយថាភូតភាពអត្តសញ្ញាណឌីជីថលជាមួយប្រព័ន្ធផ្ទៀងផ្ទាត់អត្តសញ្ញាណរួមរបស់ **ថ.ផ.ឆ.** ដើម្បីកំណត់អត្តសញ្ញាណសមាជិកនៅពេលផ្លាស់ប្តូរទិន្នន័យ
- ទទួលខុសត្រូវថែទាំហេដ្ឋារចនាសម្ព័ន្ធបណ្តាញ និងបច្ចេកទេសរបស់ខ្លួន តាមការតម្រូវរបស់ប្រតិបត្តិករ **ថ.ផ.ឆ.**
- រាយការណ៍ជូនប្រតិបត្តិកររាល់ភាពមិនប្រក្រតី លើការផ្លាស់ប្តូរទិន្នន័យតាម **ថ.ផ.ឆ.** ក្នុងរយៈពេលមិនលើសពី ២៤ (ម្ភៃបួន) ម៉ោង ក្រោយពីបានវាយតម្លៃរួច
- ចងក្រង រក្សាទុករបាយការណ៍ និងឯកសារពាក់ព័ន្ធនឹងការផ្លាស់ប្តូរទិន្នន័យតាមរយៈ **ថ.ផ.ឆ.**
- រៀបចំនិងថែរក្សាកំណត់ត្រាបច្ចេកទេសប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដើម្បីជាមូលដ្ឋានក្នុងការត្រួតពិនិត្យសន្តិសុខបច្ចេកវិទ្យាព័ត៌មាន
- សហការដោះស្រាយរាល់បញ្ហានានា ពាក់ព័ន្ធនឹងប្រតិបត្តិការ **ថ.ផ.ឆ.** ឱ្យបានឆាប់បំផុត និង
- ផ្តល់កិច្ចសហការផ្សេងទៀតតាមការស្នើសុំរបស់ប្រតិបត្តិករ **ថ.ផ.ឆ.** និង/ឬ **គ.ស.ហ.ទ.** ទាក់ទងនឹងការផ្លាស់ប្តូរទិន្នន័យតាម **ថ.ផ.ឆ.**។

## ផ្នែកទី២
## សមាជិកភាពដោយស្វ័យប្រវត្តិ

**មាត្រា១២.-**

រាល់ការផ្លាស់ប្តូរទិន្នន័យរបស់សមាជិកភាពដោយស្វ័យប្រវត្តិក្នុងក្របខណ្ឌទិន្នន័យគោល ដើម្បីផ្តល់សេវាសាធារណៈ និងក្នុងក្របខណ្ឌអន្តរប្រតិបត្តិការនៃប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ត្រូវធ្វើឡើងនៅលើ **ថ.ផ.ឆ.** តែមួយគត់។

**មាត្រា១៣.-**

សមាជិកភាពដោយស្វ័យប្រវត្តិ ត្រូវសហការនិងសម្របសម្រួលជាមួយប្រតិបត្តិករ **ថ.ផ.ឆ.** ដើម្បីរៀបចំបែបបទនិងនីតិវិធីសម្រាប់ការផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.**។

បែបបទនិងនីតិវិធីលម្អិតសម្រាប់សមាជិកភាពដោយស្វ័យប្រវត្តិផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា១៤.-**

សមាជិកភាពដោយស្វ័យប្រវត្តិ មិនអាចបោះបង់សមាជិកភាពទេ វៀរលែងតែក្នុងករណីដែលសមាជិកភាពដោយស្វ័យប្រវត្តិនោះ ត្រូវបានរំលាយចោល ឬត្រូវបានធ្វើសមាហរណកម្មជាមួយស្ថាប័នដទៃ ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ផ្នែកទី៣

## សមាជិកភាពដោយការស្នើសុំ

**មាត្រា១៥.-**

ដើម្បីអាចក្លាយជាសមាជិកភាពដោយការស្នើសុំ វិស័យឯកជន ត្រូវបំពេញពាក្យស្នើសុំទៅតាមទម្រង់និងបែបបទដែលកំណត់ដោយប្រតិបត្តិករ **ថ.ផ.ឆ.** និងត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម÷

- ជានីតិបុគ្គលដែលបានចុះបញ្ជីត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា
- បំពេញលក្ខខណ្ឌតម្រូវបច្ចេកទេសអប្បបរមា ដូចមានចែងក្នុងមាត្រា១៦ នៃអនុក្រឹត្យនេះ
- ធានាថារាល់ការទទួលយកនិងផ្លាស់ប្តូរទិន្នន័យមិនផ្តល់ការគំរាមកំហែងដល់សន្តិសុខជាតិ មិនប៉ះពាល់ដល់ភាពស្របច្បាប់នៃផលប្រយោជន៍សាធារណៈ សណ្តាប់ធ្នាប់និងផលប្រយោជន៍សង្គម សិទ្ធិឯកជនរបស់ម្ចាស់ទិន្នន័យ ឬប៉ះពាល់ដល់នយោបាយសាធារណៈរបស់រដ្ឋ និង
- បង់ថ្លៃដាក់ពាក្យស្នើសុំចូលជាសមាជិក។

សំណើសុំចូលជាសមាជិក **ថ.ផ.ឆ.** អាចត្រូវបានបដិសេធ ក្នុងករណីដែលពាក្យស្នើសុំចូលជាសមាជិក ពុំបំពេញតាមលក្ខខណ្ឌដែលបានកំណត់ក្នុងអនុក្រឹត្យនេះ និងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

បែបបទនិងនីតិវិធីលម្អិតសម្រាប់ចូលជាសមាជិកភាពដោយការស្នើសុំផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.** ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា១៦.-**

ដើម្បីក្លាយជាសមាជិកភាពដោយការស្នើសុំ បេក្ខភាពត្រូវបំពេញតាមលក្ខខណ្ឌតម្រូវអប្បបរមា ដូចតទៅ÷

- ត្រូវធានាបានថាទិន្នន័យដែលបានផ្លាស់ប្តូរតាមរយៈ **ថ.ផ.ឆ.** ត្រូវបានប្រើប្រាស់ក្នុងគោលបំណងនៃការធ្វើធុរកិច្ច និងសង្គមកិច្ច ស្របតាមអនុស្សរណៈនៃការយោគយល់គ្នា ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន

- ត្រូវធានាបាននូវគុណភាព និងសុវត្ថិភាពប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- ត្រូវមានហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ និងសម្ភារបរិក្ខារបច្ចេកវិទ្យាព័ត៌មានសួល ដើម្បីបម្រុងសម្រាប់ប្រតិបត្តិការ ធានានូវសន្តិសុខ សុវត្ថិភាព សុក្រឹតភាព និងគុណភាពប្រព័ន្ធ
- ត្រូវមានលទ្ធភាពដំឡើងម៉ាស៊ីនមេសុវត្ថិភាពក្នុងបណ្ដាញប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន និង
- ត្រូវមានសមត្ថភាពចូលរួមសហការជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ក្នុងការចាត់វិធានការឆ្លើយតបលើការវាយប្រហារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**មាត្រា១៧.-**

សមាជិកភាពដោយការស្នើសុំ ដែលមានបំណងចង់បោះបង់សមាជិកភាពពី **ថ.ផ.ឆ.** ត្រូវបំពេញនិងបង់ថ្លៃពាក្យស្នើសុំបញ្ចប់សមាជិកភាពពី **ថ.ផ.ឆ.** តាមការកំណត់ស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវសម្របសម្រួលនីតិវិធីបោះបង់សមាជិកភាព និងជូនព័ត៌មានទៅកាន់សមាជិកដទៃទៀត ជាពិសេសសមាជិកពាក់ព័ន្ធដែលជាអ្នកទទួលទិន្នន័យ និង/ឬម្ចាស់ទិន្នន័យដើម។

ការបញ្ចប់សមាជិកភាពពី **ថ.ផ.ឆ.** ត្រូវមានប្រសិទ្ធភាព គិតចាប់ពីថ្ងៃទទួលបានសេចក្ដីជូនដំណឹងស្ដីពីការបញ្ចប់សមាជិកភាពជាស្ថាពរ ដែលចេញដោយប្រតិបត្តិករ **ថ.ផ.ឆ.**។

**មាត្រា១៨.-**

ប្រតិបត្តិករ **ថ.ផ.ឆ.** មានសិទ្ធិពេញលេញក្នុងការបញ្ចប់សមាជិកភាពរបស់សមាជិកភាពដោយការស្នើសុំណាមួយក្នុងករណីរកឃើញថាសមាជិកនោះ បានប្រព្រឹត្តមិនប្រក្រតី ឬមិនគោរពតាមគោលការណ៍ ឬលក្ខខណ្ឌដែលមានចែងក្នុងអនុក្រឹត្យនេះ ឬអនុស្សរណៈនៃការយោគយល់គ្នាជាមួយប្រតិបត្តិករ ឬបានប្រព្រឹត្តល្មើសនឹងច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៥

## ប្រតិបត្តិការតាម ថ.ផ.ឆ.

**មាត្រា១៩.-**

សមាជិក **ថ.ផ.ឆ.** ត្រូវទទួលខុសត្រូវលើបន្ទុកចំណាយប្រតិបត្តិការតភ្ជាប់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួនមកកាន់ **ថ.ផ.ឆ.** ដែលមានជាអាទិ៍ ហេដ្ឋារចនាសម្ព័ន្ធបណ្ដាញ សម្ភារបរិក្ខារអេឡិចត្រូនិក និងធនធានមនុស្ស។

**មាត្រា២០.-**

ការទាញយកទិន្នន័យត្រូវរាប់ជាចំនួនប្រតិបត្តិការ ហើយម្ចាស់ទិន្នន័យដើមអាចកំណត់កម្រៃសេវាក្នុងមួយប្រតិបត្តិការនៃការទាញយកទិន្នន័យពីអ្នកទទួលទិន្នន័យ ទៅតាមប្រភេទនៃទិន្នន័យ។

វិធាននិងនីតិវិធីនៃការកំណត់កម្រៃសេវា ត្រូវកំណត់ដោយលិខិតបទដ្ឋានគតិយុត្តដោយឡែក។

**មាត្រា២១.-**

កម្រៃសេវាដែលបានមកពីប្រតិបត្តិការតាម **ថ.ផ.ឆ.** និងចំណូលផ្សេងទៀតរបស់ប្រតិបត្តិករ **ថ.ផ.ឆ.** ត្រូវចាត់ទុកជាចំណូលមិនមែនសារពើពន្ធ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ។

## ជំពូកទី៦

## វិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន

**មាត្រា២២.-**

វិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន ជាវិធីសាស្ត្រការពារតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានពីការវាយប្រហារ ដែលមានជាអាទិ៍÷

- ការលួចយកទិន្នន័យ ការកែប្រែដោយគ្មានការអនុញ្ញាត លើទិន្នន័យមូលដ្ឋានដើម និងទិន្នន័យចរាចរ
- ការព្យាយាម ឬការជ្រៀតចូលតាមគ្រប់រូបភាពទៅក្នុង **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក
- ការព្យាយាម ឬការវាយលុកធ្វើឱ្យរអាក់រអួលដល់ប្រតិបត្តិការ **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក
- ការសមគំនិត ឬការផ្តល់មធ្យោបាយ ឬការផ្តល់ជាវិធីសាស្ត្រក្នុងការវាយប្រហារប្រព័ន្ធប្រតិបត្តិការ **ថ.ផ.ឆ.** និងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់សមាជិក និង
- ការវាយប្រហារផ្សេងៗទៀតដែលបង្កហានិភ័យដល់សន្តិសុខប្រព័ន្ធអន្តរប្រតិបត្តិការ **ថ.ផ.ឆ.**។

**មាត្រា២៣.-**

រាល់សមាជិក **ថ.ផ.ឆ.** ត្រូវមានវិធានការសន្តិសុខតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរៀងៗខ្លួន ក្នុងការការពារ និងទប់ស្កាត់ការវាយប្រហារតាមប្រព័ន្ធអ៊ីនធឺណិតទៅលើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ខ្លួន ដែលប៉ះពាល់ដល់ប្រក្រតីភាពនៃដំណើរការផ្លាស់ប្តូរទិន្នន័យលើ **ថ.ផ.ឆ.** និងទិន្នន័យផ្ទាល់ខ្លួនរបស់ឯកជនដែលការពារដោយច្បាប់។

សមាជិក **ថ.ផ.ឆ.** ត្រូវរាយការណ៍ជូនប្រតិបត្តិករ **ថ.ផ.ឆ.** ពីហានិភ័យដែលអាចបង្កឡើង និង/ឬប៉ះពាល់ដល់សុវត្ថិភាព **ថ.ផ.ឆ.** និងត្រូវសហការជាមួយប្រតិបត្តិករ **ថ.ផ.ឆ.** ដើម្បីរកដំណោះស្រាយ។

**មាត្រា២៤.-**

ប្រតិបត្តិករ និងសមាជិក **ថ.ផ.ឆ.** ត្រូវរៀបចំឱ្យមានការត្រួតពិនិត្យវាយតម្លៃលើសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.** តាមការចាំបាច់ ដោយស្ថាប័នជំនាញ។ ប្រតិបត្តិករ **ថ.ផ.ឆ.** មានកាតព្វកិច្ចអនុវត្តតាមរបាយការណ៍ត្រួតពិនិត្យវាយតម្លៃ និងធ្វើការជួសជុលចំណុចខ្វះខាតដែលអាចគំរាមកំហែងដល់សន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានរបស់ **ថ.ផ.ឆ.**។

## ជំពូកទី៧

## អវសានប្បញ្ញត្តិ

**មាត្រា២៥.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា២៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១ រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ឧបសម្ព័ន្ធទី ១ នៃអនុក្រឹត្យលេខ ១៦៤ អនក្រ.បក**

**ស្ដីពីការផ្លាស់ប្ដូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្ដូរទិន្នន័យកម្ពុជា**

**ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១**

**សន្ទានុក្រម**

**ក**

កូដនីយកម្ម (Encryption) សំដៅដល់ការបំប្លែងព័ត៌មាន ឬទិន្នន័យទៅជាកូដពិសេសណាមួយដែលគេមិនអាចយល់ ឬប្រើប្រាស់បាន។

កំណត់ត្រាអេឡិចត្រូនិក (Timestamp) សំដៅដល់កំណត់ត្រាដែលត្រូវបានបង្កើតឡើង ទាក់ទង ទទួល រក្សាទុក ឬដំណើរការក្នុងប្រព័ន្ធអេឡិចត្រូនិក ឬសម្រាប់បញ្ជូនពីប្រព័ន្ធអេឡិចត្រូនិកមួយទៅប្រព័ន្ធអេឡិចត្រូនិកមួយទៀត។

**ច**

ចំនួនប្រតិបត្តិការ (Number of transaction) សំដៅដល់ចំនួននៃការស្នើសុំទិន្នន័យមកកាន់អ្នកផ្ដល់ទិន្នន័យដែលមួយប្រតិបត្តិការត្រូវបានកំណត់យកនៅពេលដែលអ្នកផ្ដល់ទិន្នន័យឆ្លើយតបទៅវិញដោយជោគជ័យតាមតម្រូវការនៃការស្នើសុំទិន្នន័យនោះ។

**ទ**

ទិន្នន័យគោល (Base registry) សំដៅដល់ទិន្នន័យមូលដ្ឋានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នមានសមត្ថកិច្ចដែលជាម្ចាស់ទិន្នន័យដើម ហើយមានតែម្ចាស់ទិន្នន័យដើមទេដែលមានសិទ្ធិធ្វើបច្ចុប្បន្នភាពទិន្នន័យទាំងនោះស្របតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន មានជាអាទិ៍ ទិន្នន័យអត្រានុកូលដ្ឋាន ទិន្នន័យបញ្ជាក់អត្តសញ្ញាណ (លិខិតឆ្លងដែន, បណ្ណបើកបរ, បណ្ណរបបសន្តិសុខសង្គម) ទិន្នន័យយានយន្ត ទិន្នន័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទិន្នន័យធុរកិច្ច ទិន្នន័យអចលនវត្ថុ ទិន្នន័យភូមិសាស្ត្រ ទិន្នន័យចំណូលសារពើពន្ធនិងមិនមែនសារពើពន្ធ ទិន្នន័យអប់រំ ទិន្នន័យការងារ ទិន្នន័យធានារ៉ាប់រង ទិន្នន័យរបបសន្តិសុខសង្គម ទិន្នន័យសុខាភិបាល និងទិន្នន័យរដ្ឋបាលថ្នាក់ក្រោមជាតិ។

ទិន្នន័យមូលដ្ឋាន (Database) សំដៅដល់បណ្ដុំនៃទំនាក់ទំនងទិន្នន័យ ឬព័ត៌មានដែលរក្សាទុកក្នុងកុំព្យូទ័រតាមវិធីណាមួយ ដោយក្នុងនោះ វាផ្ដល់ភាពងាយស្រួលក្នុងការមើល បន្ថែម ស្វែងរក ឬធ្វើបច្ចុប្បន្នភាពទិន្នន័យ។

**ប**

បរិវត្តកម្មឌីជីថល (Digital transformation) សំដៅដល់សមាហរណកម្មនៃបច្ចេកវិទ្យាឌីជីថល នៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គម ដើម្បីជំរុញប្រសិទ្ធភាពសេដ្ឋកិច្ច ទំនាក់ទំនងសង្គម និងផលិតភាពនៃប្រតិបត្តិការការងារ។

ម

ម៉ាស៊ីនមេសុវត្ថិភាព (Security server) សំដៅដល់ម៉ាស៊ីនមេដែលមានតួនាទីផ្ទៀងផ្ទាត់ការស្នើសុំឆ្លើយតប (request-response) របស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានដែលធ្វើការផ្លាស់ប្តូរទិន្នន័យប្រកបដោយសុវត្ថិភាព ហើយមានតួនាទីជាអ្នកធ្វើកូដនីយកម្ម និងវិកូដនីយកម្មលើទិន្នន័យ។

ម្ចាស់ទិន្នន័យដើម (Original data owner) សំដៅដល់ក្រសួង-ស្ថាប័នដែលមានសិទ្ធិអំណាចពេញលេញកាន់កាប់ទិន្នន័យជារបស់ខ្លួន និងដែលមានសមត្ថកិច្ចក្នុងការធ្វើបច្ចុប្បន្នភាពទិន្នន័យ។

យ

យថាភូតភាព (Authenticity) សំដៅដល់ការបញ្ជាក់អត្តសញ្ញាណអ្នកប្រើប្រាស់កុំព្យូទ័រក្នុងគោលបំណងសន្តិសុខ ដោយការផ្ទៀងផ្ទាត់ (ឈ្មោះ លេខសម្ងាត់ កាត ក្រយៅដៃ សំឡេង ភ្នែក មុខ ។ល។)។

ស

សន្តិសុខបច្ចេកវិទ្យាព័ត៌មាន (Cyber security) សំដៅដល់បច្ចេកវិទ្យាប្រឆាំងនឹងការប្រើប្រាស់ទិន្នន័យព័ត៌មានដោយគ្មានការអនុញ្ញាត។

សន្ធានកម្មនៃកម្មវិធីកុំព្យូទ័រ (Application Programming Interface ឬហៅកាត់ថា API) សំដៅដល់ច្រកចេញចូលស្តង់ដារដែលអនុញ្ញាតឱ្យទិន្នន័យអាចផ្លាស់ប្តូរពីប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយ ទៅប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានមួយផ្សេងទៀត។ ការផ្លាស់ប្តូរទិន្នន័យ គឺតម្រូវឱ្យស្របតាមលក្ខខណ្ឌដែលបានកំណត់។

ហ

ហត្ថលេខាឌីជីថល (Digital signature) សំដៅដល់ទិន្នន័យដែលភ្ជាប់នឹងសារអេឡិចត្រូនិក ដើម្បីបញ្ជាក់អត្តសញ្ញាណនៃហត្ថលេខីឌីជីថល និងផ្ទៀងផ្ទាត់ស្ថានភាពដើមនៃសារអេឡិចត្រូនិក ដែលហត្ថលេខីឌីជីថលបានចុះហត្ថលេខា។

ឧ

ឧក្រិដ្ឋកម្មឌីជីថល (Digital crime) សំដៅដល់ការប្រព្រឹត្តអំពើល្មើសនានា តាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន។

**ឧបសម្ព័ន្ធទី ២ នៃអនុក្រឹត្យលេខ ១៦៤ អនក្រ.បក**
**ស្តីពីការផ្លាស់ប្តូរទិន្នន័យ តាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា**
**ចុះថ្ងៃទី ២៤ ខែ សីហា ឆ្នាំ២០២១**

**គំនូសតាងប្រព័ន្ធអន្តរប្រតិបត្តិការ ថ.ផ.ទ.**




(1) **សមាសភាគស្នូល** (Core Component) មានតួនាទីគ្រប់គ្រងម៉ាស៊ីនមេសុវត្ថិភាព និងគ្រប់គ្រងប្រតិបត្តិការទូទៅក្នុង **ថ.ផ.ទ.**។

(2) **ម៉ាស៊ីនមេសុវត្ថិភាព** (Security Server) មានតួនាទីជាច្រកចេញចូលនៃសន្ទានកម្មនៃកម្មវិធីកុំព្យូទ័រ (API Gateway) និងជាអ្នកធានាសុវត្ថិភាពនិងសុចរិតភាពការផ្លាស់ប្តូរទិន្នន័យ តាមរយៈការធ្វើកូដនីយកម្ម ការចុះហត្ថលេខាឌីជីថល និងការធ្វើកំណត់ត្រាអេឡិចត្រូនិកនៃប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យម្តងៗ។ ម៉ាស៊ីនមេសុវត្ថិភាព គឺជាសមាជិករបស់ **ថ.ផ.ទ.**។

(3) **ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានផ្តល់ និងទទួលទិន្នន័យ** (Data Provider and Consumer) ជាអ្នកផ្តល់ និងទទួលទិន្នន័យ ដែលត្រូវតភ្ជាប់ជាមួយម៉ាស៊ីនមេសុវត្ថិភាព ដើម្បីធានាសុវត្ថិភាពនិងសុចរិតភាពទិន្នន័យពេលផ្លាស់ប្តូរទិន្នន័យ។

(4) **សមាសភាគផ្តល់ទំនុកចិត្ត** (Trusted Component) ជាអ្នកគ្រប់គ្រងវិញ្ញាបនបត្រឌីជីថល (Digital Certificate) សម្រាប់ប្រើប្រាស់ក្នុងការកំណត់អត្តសញ្ញាណសមាជិក និងធ្វើកូដនីយកម្ម/វិកូដនីយកម្មពេលផ្លាស់ប្តូរទិន្នន័យ និងជាអ្នកធ្វើកំណត់ត្រាអេឡិចត្រូនិកនៃរាល់ប្រតិបត្តិការផ្លាស់ប្តូរទិន្នន័យ។

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៥៨៣ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនហ្វ្រីនត្រេដ អាណត្តិទី៨

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៦៩៦/០៣ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ
- បានឃើញអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្វ្រីនត្រេដ
- បានឃើញអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការកែប្រែមាត្រា៧ នៃអនុក្រឹត្យ៧២ អនក្រ.បក ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការបង្កើតក្រុមហ៊ុនហ្វ្រីនត្រេដ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

## សម្រេច

**មាត្រា១.-**

ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនហ្វ្រីនត្រេដ អាណត្តិទី៨ ដែលមានសមាសភាពដូចខាងក្រោម៖

១- ឯកឧត្តម **ចាន់ សុខទី** ប្រធានអគ្គនាយកក្រុមហ៊ុនហ្វ្រីនត្រេដ ប្រធាន

៩

| | | | |
|---|---|---|---|
| ២- ឯកឧត្តម | **ស៊ាង ថៃ** | តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៣- ឯកឧត្តម | **ឆាំង ហ៊ុយ** | តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៤- ឯកឧត្តម | **ពាង សាវី** | តំណាងក្រសួងផែនការ | សមាជិក |
| ៥- លោក | **ណី សាគល** | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦- លោក | **ជា ច័ន្ទវាសនា** | តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- លោក | **រ៉ែន បាឌ្មែន** | តំណាងនិយោជិតក្រុមហ៊ុនហ្វ្រីនត្រេដ | សមាជិក។ |

**មាត្រា២.-**

អនុក្រឹត្យលេខ១១៧៤ អនក្រ.តត ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៨ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលក្រុមហ៊ុនហ្វ្រីដត្រេដ អាណត្តិទី៧ និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ពុធ ៣រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៩៥៤ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពីការបញ្ចប់មុខតំណែងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- យោងតាមសំណើរបស់ឯកឧត្តម ហូ សិទ្ធី ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស

## សម្រេច

**មាត្រា១** : បញ្ចប់មុខតំណែងលោក **ខុច ណារ៉ូ** ពីជំនួយការរបស់ឯកឧត្តម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស។

**មាត្រា២** : តែងតាំង និងផ្តល់ឋានៈដល់លោក **ញ៉ែម និច័ន្ត** ជាជំនួយការរបស់ឯកឧត្តម **ហូ សិទ្ធី** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស មានឋានៈស្មើ ប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ជំនួសលោក ខុច ណារ៉ូ។

**មាត្រា៣** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា១ និងមាត្រា២ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៥៨៥ អនក្រ.តត

# អនុក្រឹត្យ

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ៤៨៩ អនក្រ.បក ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តែងតាំងលោក **ចាប ប៉ុណ្ណារ៉ា** ជាប្រធានផ្នែកស្រាវជ្រាវព័ត៌មាន បណ្តុះបណ្តាល និងចលនាមហាជន នៃអគ្គលេខាធិការដ្ឋានគណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្មនៅតាមគ្រប់មុខសញ្ញា នៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានឋានៈស្មើប្រធាននាយកដ្ឋាន ជំនួសលោក **សំ ស៊ីដេត** ដែលបានផ្ទេរចេញ។

**មាត្រា ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ៨រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ- កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១១៨ សសរ

## សេចក្តីសម្រេច

## ស្តីពី

## ការផ្លាស់ប្តូរសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ និងខេត្តកំពត ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ៩២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០២១ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានរាជធានី ខេត្ត
- យោងសេចក្តីណែនាំលេខ ០១ សណន ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០១៩ ស្តីពីតួនាទី ភារកិច្ច និងរបៀបរបបការងារសម្រាប់ក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានរាជធានី ខេត្ត ក្នុងការបំពេញបេសកកម្ម ដើម្បីត្រួតពិនិត្យ និងគាំទ្រកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាល
- យោងកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៦ នៃរដ្ឋសភា
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជា

## សម្រេច

**ប្រការ១ .-**

ត្រូវបានផ្លាស់ប្តូរ ឯកឧត្តម **កាន ច័ន្ទមេត្តា** រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ពីសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋានខេត្តព្រះសីហនុ មកជាសមាជិកក្រុមការងាររាជរដ្ឋាភិបាលចុះមូលដ្ឋាន**ខេត្តកំពត** ដើម្បីត្រួតពិនិត្យ និងគាំទ្រការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជា។

**ប្រការ២ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ រដ្ឋបាលខេត្តព្រះសីហនុ រដ្ឋបាលខេត្តកំពត និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

ថ្ងៃព្រហស្បតិ៍ ១៣កើត ខែ កត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ២០២១

**តប.នាយករដ្ឋមន្ត្រី**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

<u>កន្លែងទទួល:</u>

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី*
- *ដូចប្រការ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ០៧ សរណន

## សារាចរណែនាំ
## ស្តីពី
## ការអនុវត្តការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២

យោងការសម្រេចរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០ លើលិខិតលេខ៨៣៥៨ សហវ.អថ ចុះថ្ងៃទី៥ ខែតុលា ឆ្នាំ២០២០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងការសម្រេចរបស់រាជរដ្ឋាភិបាលចុះថ្ងៃទី២ ខែតុលា ឆ្នាំ២០២១ លើលិខិតលេខ៨២១៩ សហវ ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០២១ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសំណើ របស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រាជរដ្ឋាភិបាល ដាក់ចេញនូវការណែនាំការអនុវត្តការដំឡើងឋានន្តរស័ក្តិ និងថ្នាក់សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២ ដូចខាងក្រោម៖

**១**- ការដំឡើងឋានន្តរស័ក្តិ និងថ្នាក់ ជូនមន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិលផ្សេងទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទ សម្រាប់ឆ្នាំ២០២១ និងឆ្នាំ២០២២ ត្រូវអនុវត្តជាធម្មតាអនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**២**-ការបម្រែបម្រួលស្ថានភាពថវិកានៅក្នុងតារាងទូទាត់បៀវត្សសម្រាប់មន្ត្រីរាជការស៊ីវិលនៃក្រុមនីតិប្បញ្ញត្តិ នីតិប្រតិបត្តិ តុលាការ មន្ត្រីរាជការស៊ីវិលផ្សេងទៀត មន្ត្រីនគរបាលជាតិ មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងយោធិននៃកងយោធពលខេមរភូមិន្ទដែលត្រូវបានដំឡើងឋានន្តរស័ក្តិ និងថ្នាក់នៅឆ្នាំ២០២១ និងឆ្នាំ២០២២ ត្រូវអនុវត្តចាប់ពីខែឧសភា ឆ្នាំ២០២២ ដោយមិនមានការអនុវត្តប្រតិសកម្មឡើយ។

ទទួលបានសារាចរណែនាំនេះ គ្រប់ក្រសួង ស្ថាប័ន រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់៕

ថ្ងៃ សុក្រ ១២ រោច ខែ មិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០២១

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
លេខ: [illegible]

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

# ប្រកាសរួម
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី ៣០ ខែមីនា ឆ្នាំ ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ០៦ ខែកញ្ញា ឆ្នាំ ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៥១៨/៥៩០ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកែសម្រួលមាត្រាមួយចំនួននៃព្រះរាជក្រឹត្យលេខ នស/រកត/០៨១៥/៨៧២ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៥ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១១២/០០៨ ចុះថ្ងៃទី ១៤ ខែមករា ឆ្នាំ ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញ ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែតុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ អនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ ២០០៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ១០ អនក្រ.បក ចុះថ្ងៃទី ១៧ ខែកុម្ភៈ ឆ្នាំ ២០២០ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញ អនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញ អនុក្រឹត្យលេខ ៨៥៦ អនក្រ.បក ចុះថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០២០ ស្តីពីការតែងតាំងក្រុមប្រឹក្សាភិបាលនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ
- បានឃើញ អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញ អនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការ កំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
- បានឃើញ អនុក្រឹត្យលេខ ១៥ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៩ ស្តីពីការគ្រប់គ្រងថវិកានិងទ្រព្យសម្បត្តិរដ្ឋនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅរបស់សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ សរសេរជាអក្សរកាត់ថា ស.ភ.វ.ស. ។

**ប្រការ២.-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគ្រប់អង្គភាពទាំងអស់របស់ ស.ភ.វ.ស. ។

## ជំពូកទី២

## បេសកកម្ម មុខងារ ភារកិច្ច និងរចនាសម្ព័ន្ធ

## ផ្នែកទី១

## បេសកកម្ម មុខងារ និងភារកិច្ច

**ប្រការ៣.-**

ស.ភ.វ.ស. បំពេញមុខងារជាសេនាធិការឱ្យក្រសួងវប្បធម៌និងវិចិត្រសិល្បៈលើបេសកកម្មដឹកនាំបណ្តុះបណ្តាលធនធានមនុស្ស និងស្រាវជ្រាវផ្នែកសិល្បៈ វប្បធម៌ក្នុងនាមជានីតិបុគ្គលនៃនីតិសាធារណៈ ។

**ប្រការ៤.-**

ស.ភ.វ.ស. មានមុខងារ និងភារកិច្ចដូចតទៅ÷

- អភិវឌ្ឍកម្មវិធីសិក្សាឱ្យសមស្របតាមគោលនយោបាយជាតិស្តីពីវិស័យវប្បធម៌របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈនិងគោលនយោបាយជាតិស្តីពីចក្ខុវិស័យឧត្តមសិក្សា២០៣០ របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំ និងកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារៈរូបវ័ន្តសម្រាប់បម្រើការបណ្តុះបណ្តាលប្រកបដោយគុណភាព
- បង្កើនសមត្ថភាពសាស្ត្រាចារ្យ បុគ្គលិក តាមរយៈការផ្លាស់ប្តូរបទពិសោធន៍ ការសិក្សាស្រាវជ្រាវ ការបណ្តុះបណ្តាលបន្តរយៈពេលខ្លី មធ្យម និងវែង
- រៀបចំផែនការកសាងសមត្ថភាព និងធ្វើវិក្រឹតការគ្រូបង្រៀន និងបុគ្គលិកជំនាញ បច្ចេកទេសឱ្យសមស្របតាមសំណូមពរនិងតម្រូវការជាក់ស្តែង

- ដំណើរការប្រឡងជ្រើសរើសនិស្សិតដែលមានទេពកោសល្យសិល្បៈ និងវាយតម្លៃការសិក្សាឱ្យបានត្រឹមត្រូវតាមគោលការណ៍ប្រកបដោយតម្លាភាព
- ផ្តល់ជូននិស្សិតនូវការអប់រំប្រកបដោយគុណភាព និងជំនាញច្បាស់លាស់លើវិស័យសិល្បៈវប្បធម៌ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារ និងសង្គម
- បណ្តុះបណ្តាលវិជ្ជាជីវៈសិល្បៈព្រមទាំងបន្តបណ្តុះបណ្តាលអ្នកឯកទេស អ្នកជំនាញប្រកបដោយគុណភាព និងផ្តល់វិញ្ញាបនបត្រ សញ្ញាបត្រ តាមការចាំបាច់របស់សាកលវិទ្យាល័យ
- លើកស្ទួយការងារស្រាវជ្រាវវិទ្យាសាស្ត្រផ្នែកសិល្បៈ វប្បធម៌ ចងក្រង បោះពុម្ព និងផ្សព្វផ្សាយឱ្យបានទូលំទូលាយក្នុងកម្រិតជាតិ តំបន់ និងអន្តរជាតិ
- ពង្រឹងទំនាក់ទំនងជាមួយសាកលវិទ្យាល័យជាតិ និងដៃគូសហប្រតិបត្តិការអន្តរជាតិ និងផ្តល់នូវវិញ្ញាបនបត្រ សញ្ញាបត្រតាមកម្រិតនៃការបណ្តុះបណ្តាល
- រៀបចំគម្រោង និងថវិកាពីដៃគូអភិវឌ្ឍន៍ អង្គការដៃគូជាតិ វិស័យឯកជននានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍនៃផែនការយុទ្ធសាស្ត្រតាមដំណាក់កាលនីមួយៗរបស់សាកលវិទ្យាល័យខ្លួន។

## ផ្នែកទី២
## រចនាសម្ព័ន្ធ

**ប្រការ៥.-**

អង្គភាពប្រតិបត្តិរបស់ ស.ភ.វ.ស. មានរចនាសម្ព័ន្ធដូចខាងក្រោម÷

ក. លេខាធិការដ្ឋាន

ខ. សិក្សាធិការដ្ឋាន

គ. មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌ និងនវានុវត្តន៍

ឃ. មហាវិទ្យាល័យចំនួន៥

ស.ភ.វ.ស. មានអង្គភាពសវនកម្មមួយជាសេនាធិការលើកិច្ចការសវនកម្ម ។

ស.ភ.វ.ស. មានគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្ម ជាសេនាធិការលើការងារលទ្ធកម្មសាធារណៈ និងគណៈកម្មការរៀបចំបញ្ជីសារពើភណ្ឌ ជាសេនាធិការលើការងារបញ្ជីសារពើភណ្ឌដែលត្រូវបង្កើតអនុលោមតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ។

អង្គការលេខរបស់ ស.ភ.វ.ស. ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ ។

**ប្រការ៦.-**

ស.ភ.វ.ស. គ្រប់គ្រងដោយសាកលវិទ្យាធិការ ១ (មួយ)រូប មានតួនាទីជានាយកប្រតិបត្តិ និងអមដោយសាកលវិទ្យាធិការរងជាជំនួយការ ចំនួនច្រើនបំផុត ៥ (ប្រាំ)រូប ។

លេខាធិការដ្ឋាន សិក្សាធិការដ្ឋាន មជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍ ដឹកនាំដោយប្រធាន ១ (មួយ)រូប និងអមដោយអនុប្រធានជាជំនួយការ ចំនួនច្រើនបំផុត ៣ (បី)រូប ។

មហាវិទ្យាល័យនីមួយៗ ដឹកនាំដោយព្រឹទ្ធបុរស ១ (មួយ)រូប និងអមដោយព្រឹទ្ធបុរសរងជាជំនួយការ ចំនួនច្រើនបំផុត ៤ (បួន)រូប ។

ការិយាល័យនីមួយៗដឹកនាំដោយប្រធាន ១ (មួយ) រូប និងអនុប្រធានជាជំនួយការចំនួនច្រើនបំផុត៣ (បី) រូប ។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យ និងអង្គភាពប្រហាក់ប្រហែលក្រោមឱវាទ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

សាកលវិទ្យាធិការរង ប្រធានលេខាធិការដ្ឋាន ប្រធានសិក្សាធិការដ្ឋាន ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍ និងព្រឹទ្ធបុរសមហាវិទ្យាល័យ ត្រូវតែងតាំង និងបញ្ចប់ពីមុខតំណែងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ។

ព្រឹទ្ធបុរសរង អនុប្រធានលេខាធិការដ្ឋាន អនុប្រធានសិក្សាធិការដ្ឋាន អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌និងនវានុវត្តន៍ និងប្រធានការិយាល័យចុះក្រោមត្រូវតែងតាំង និងបញ្ចប់ពីមុខតំណែងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈតាមសំណើរបស់សាកលវិទ្យាធិការដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល ។

## ជំពូកទី៣
## លេខាធិការដ្ឋាន

**ប្រការ៧.-**

លេខាធិការដ្ឋាន មានមុខងារ និងភារកិច្ចដូចតទៅ÷

- រៀបចំផែនការ និងដំណើរការកសាងផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែងរបស់ ស.ភ.វ.ស.
- រៀបចំផែនការរំកិលក្នុងការអនុវត្តផែនការយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែងរបស់ ស.ភ.វ.ស.
- រៀបចំផែនការតាមដានត្រួតពិនិត្យផ្ទៃក្នុងនៃការអនុវត្តផែនការយុទ្ធសាស្ត្ររបស់ ស.ភ.វ.ស.
- រៀបចំឯកសារក្នុងដំណើរការជ្រើសរើសអ្នកប្រឹក្សាឯករាជ្យ និងសហការក្នុងដំណើរនៃការវាយតម្លៃពាក់កណ្តាល និងចុងបញ្ចប់នៃផែនការយុទ្ធសាស្ត្រ
- គ្រប់គ្រង និងអភិវឌ្ឍប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងរបស់សាកលវិទ្យាល័យ

- រៀបចំ តាមដានការអនុវត្តនូវគោលនយោបាយ និងអភិវឌ្ឍន៍មុខងាររដ្ឋបាល គណនេយ្យនិងហិរញ្ញវត្ថុ ធនធានមនុស្ស ទំនាក់ទំនងអន្តរជាតិ ព័ត៌មាននិងផ្សព្វផ្សាយ
- សហការជាមួយក្រុមប្រឹក្សាគុណភាពក្នុងដំណើរការវាយតម្លៃផ្ទៃក្នុងលើស្តង់ដារ ១, ២, ៧, ៩ នៃសៀវភៅណែនាំស្តីពី "**ការអនុវត្តស្តង់ដារជាតិ និងនិទ្ទេសបទសម្រាប់ការវាយតម្លៃការផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា**"
- សហការក្នុងដំណើរការវាយតម្លៃពីខាងក្រៅរបស់ក្រុមការងារនៃគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជាក្នុងការវាយតម្លៃគុណភាពអប់រំរបស់ ស.ភ.វ.ស.
- គ្រប់គ្រងទ្រព្យសម្ភារគ្រប់ប្រភេទ ដែលពាក់ព័ន្ធនឹងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- គ្រប់គ្រងការប្រមូលចំណូល និងទូទាត់ចំណាយរបស់ស.ភ.វ.ស.
- កាន់កាប់បញ្ជីគណនេយ្យ និងរក្សាទុកលិខិតយុត្តិការច្បាប់ដើម
- រៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ស.ភ.វ.ស. ស្របតាមគោលនយោបាយយុទ្ធសាស្ត្រ ដែលក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានកំណត់ និងផែនការសកម្មភាពរបស់ស.ភ.វ.ស. ដែលសម្រេចដោយក្រុមប្រឹក្សាភិបាល
- រៀបចំផែនការអភិវឌ្ឍន៍ គម្រោងថវិកាប្រចាំឆ្នាំ និងគម្រោងវិនិយោគរបស់ ស.ភ.វ.ស.
- ទំនាក់ទំនងជាមួយក្រសួងអាណាព្យាបាលទាំងពីរពាក់ព័ន្ធនឹងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យថវិការបស់ ស.ភ.វ.ស.
- គ្រប់គ្រងនិងចាត់ចែងការអនុវត្តថវិកា ស្របតាមគោលការណ៍ហិរញ្ញវត្ថុជាធរមាន
- តាមដានលទ្ធផលនៃការអនុវត្តថវិកា
- សម្របសម្រួលក្នុងនាមជាសេនាធិការរបស់សាកលវិទ្យាធិការសម្រាប់ការតាមដាន ត្រួតពិនិត្យការធ្វើអធិការកិច្ច និងសវនកម្ម
- រៀបចំរបាយការណ៍ហិរញ្ញវត្ថុអនុលោមតាមស្តង់ដាគណនេយ្យ របាយការណ៍អនុវត្តថវិកា(ចំណូល-ចំណាយ) និងរបាយការណ៍សមិទ្ធកម្មរបស់ស.ភ.វ.ស.ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមានជូនប្រធានក្រុមប្រឹក្សាភិបាលដើម្បីពិនិត្យ អនុម័ត រួចផ្ញើជូនរដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ទទួលអនុវត្តភារកិច្ចផ្សេងទៀតពីថ្នាក់ដឹកនាំសាកលវិទ្យាល័យនិងថ្នាក់ដឹកនាំក្រសួងប្រគល់ជូន ។

**ប្រការ៨.-**

